# គោលការណ៍ណែនាំទាក់ទងនឹងមេរោគឆ្លងកូវីដ-១៩[1]
# ស្តីពីការការពារអ្នករស់នៅតាមសំណង់មិនរៀបរយ


## លោកស្រី ឡីឡានី ហ្វាហា

### អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិមានលំនៅឋានសមរម្យ


### បានធ្វើបច្ចុប្បន្នភាព ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០

លំនៅឋានបានក្លាយជាទីកន្លែងការការពារជួរមុខប្រឆាំងនឹងមេរោគកូរ៉ូណា ហើយលំនៅឋានក៏បានក្លាយជាស្ថានភាពស្លាប់រស់កាន់តែខ្លាំងឡើង។

ដើម្បីបង្ការការរីករាលដាលនៃមេរោគកូវីដ-១៩ រដ្ឋនានានៅទូទាំងពិភពលោកកំពុងស្នើសុំ និងក្នុងករណីខ្លះបានធ្វើច្បាប់ តម្រូវឲ្យប្រជាពលរដ្ឋ "នៅផ្ទះ"។ ការធ្វើបែបនេះដោយផ្អែកតាមការសន្មត់ថា ការនៅតែក្នុងផ្ទះរបស់ប្រជាពលរដ្ឋ គឺជួយការពារពួកគេពីការឆ្លង និងការរីករាលដាលមេរោគ។ ការណ៍នេះមិនមែនជានិច្ចកាលជួយបានគ្រប់ករណីនោះទេ។

យ៉ាងហោចណាស់ មានមនុស្ស មួយពាន់លាននាក់កំពុងរស់នៅតាមសំណង់មិនរៀបរយ ឬ តាមទីតាំងលក្ខណៈប្រមូលផ្តុំមិនរៀបរយ ដែលក្នុងនោះ មានមួយភាគបួននៃប្រជាជនរស់នៅតាមទីក្រុងនៅលើពិភពលោក។ នៅតាមតំបន់សំណង់មិនរៀបរយ លក្ខខណ្ឌរស់នៅតែងតែមិនមានភាពគ្រប់គ្រាន់ជាខ្លាំងសូម្បីតែនៅអំឡុងពេលស្ថានភាពល្អប្រសើរ ។ ប្រជាជនរស់នៅតាមលំនៅឋានមិនរៀបរយ មិនមានទឹកប្រើប្រាស់ដែលរកបាននៅលើទីតាំង ឬខ្វះអនាម័យ មានភាពចង្អៀតណែន និងប្រឈមនឹងការគំរាមកំហែងបណ្តេញចេញដោយបង្ខំជាប្រចាំ។ ការលាងសម្អាតដៃ, ការសម្លាប់មេរោគ, ការរក្សាគម្លាតពីគ្នា

---

[1] គោលការណ៍ណែនាំនេះ បានត្រូវធ្វើឡើងតាមរយៈកិច្ចពិគ្រោះយោបល់ជាមួយអ្នកតស៊ូមតិមកពី អាស៊ី អាហ្វ្រិក អឺរ៉ុប អាមេរិកខាងជើង និងអាមេរិកឡាទីន។ គោលការណ៍ណែនាំនេះ អាចត្រូវធ្វើបច្ចុប្បន្នភាពជាបន្តទៀតដោយបញ្ចូលនូវដំបូន្មានរបស់អ្នកជំនាញការ ការអនុវត្តល្អៗ ឬមេរៀនបទពិសោធន៍ ។

និងការដាក់អ្នកដែលឆ្លងមេរោគឲ្យនៅដាច់ដោយឡែក ដែលជាកត្តាចាំបាច់សម្រាប់ទប់ស្កាត់មេរោគឆ្លង កូវីដ-១៩ តែងតែមិនអាចអនុវត្តទៅបាន។

លុះត្រាតែរដ្ឋាភិបាល បង្កើននូវវិធានការបន្ទាន់នានាដើម្បីជួយសហគមន៍ក្នុងការដោះស្រាយលក្ខខណ្ឌមិនល្អទាំងនេះ បើមិនដូច្នោះទេ មេរោគកូវីដ-១៩ អាចរីករាលដាលដូចភ្លើងឆេះព្រៃ ដែលវានឹងធ្វើអោយជីវិតមនុស្សដ៏ច្រើនប្រឈមនឹងហានិភ័យទាំងក្នុង និងក្រៅតំបន់ទីលំនៅមិនរៀបរយទាំងអស់នោះ។ វាជាការសំខាន់ចាំបាច់ណាស់ ដែលរដ្ឋត្រូវទទួលស្គាល់ថា អ្នកដែលរស់នៅតាមសំណង់/ទីតាំងលក្ខណៈប្រមូលផ្តុំមិនរៀបរយទាំងនេះ ងាយរងគ្រោះនឹងការឆ្លងមេរោគ ហើយដែលបង្កើនហានិភ័យនៃការឆ្លងលក្ខណៈសហគមន៍។

នៅក្នុងបរិបទនេះ រដ្ឋ ត្រូវតែដោះស្រាយតម្រូវការខាងលំនៅឋានរបស់អ្នករស់នៅតាមសំណង់និងទីតាំងលក្ខណៈប្រមូលផ្តុំមិនរៀបរយជាបន្ទាន់ និងជាអាទិភាព ដើម្បីធានាឲ្យមានការការពារស្មើគ្នាប្រឆាំងនឹងមេរោគឆ្លង និងការការពារចំពោះប្រជាជនទូទៅ។ កិច្ចការនេះទាមទារឲ្យមានកិច្ចសហការរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីមានធនធានចាំបាច់ និងមានសមត្ថភាពដែលធានាបានថាកិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃមេរោគនេះអនុវត្តដោយប្រសិទ្ធភាព។ រដ្ឋទាំងឡាយ ដោយប្រកាន់ខ្ជាប់នូវកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន ត្រូវតែចាត់វិធានការបន្ទាន់នានាដូចខាងក្រោម៖

១- ប្រកាសបញ្ឈប់រាល់ការបណ្តេញចេញដោយបង្ខំចំពោះ អ្នកដែលរស់នៅតាមសំណង់មិនរៀបរយ និងទីតាំងរស់នៅលក្ខណៈប្រមូលផ្តុំមិនរៀបរយ។ ធានាថា ធនធានចាំបាច់នានាមានសម្រាប់អនុវត្តបទបញ្ជានេះប្រកបដោយប្រសិទ្ធភាព រួមទាំងធនធានដើម្បីតាមដាន និងទប់ស្កាត់ការបណ្តេញចេញក្នុងទម្រង់ក្រៅច្បាប់។

២- ដាក់កំហិតនូវបំរាមហាមឃាត់លើដំណើរការបន្ទាន់ណាមួយ ដូចជា "ការធ្វើអោយចុះថយចំនួនប្រជាជន" ដែលពាក់ព័ន្ធនឹងការបណ្តេញចេញក្នុងចំនួនដ៏ច្រើន ពីតំបន់តាំងទីលំនៅមិនរៀបរយ/ទីតាំងរស់នៅលក្ខណៈប្រមូលផ្តុំមិនរៀបរយ។ ជំនួសមកវិញ ត្រូវដាក់ជាអាទិភាពដោយធានាឲ្យតំបន់តាំងទីលំនៅមិនរៀបរយ/ទីតាំងរស់នៅលក្ខណៈប្រមូលផ្តុំ មាននូវសម្ភារបរិក្ខារសម្រាប់គ្រប់គ្រងការរីករាលដាលមេរោគឆ្លង រួមមាន ទីតាំងសុវត្ថិភាពចត្តាឡីស័កសម្រាប់ដាក់អ្នកដែលមានលទ្ធផលវិជ្ជមាននៃមេរោគ ឬអ្នកមានរោគសញ្ញានៃមេរោគឲ្យនៅដាច់ដោយឡែក។

៣- ធានាថា ប្រជាជនរស់នៅតាមសំណង់មិនរៀបរយ/ទីតាំងរស់នៅលក្ខណៈប្រមូលផ្តុំមិនរៀបរយ មានលទ្ធភាពប្រើប្រាស់ និងទទួលបានយ៉ាងគ្រប់គ្រាន់នូវការផ្គត់ផ្គង់ទឹកស្អាតនៅជិតសហគមន៍របស់ពួកគេ បង្គន់អនាម័យ ទឹកសម្រាប់ងូត សេវាអនាម័យ សាប៊ូ ទឹកលាងសម្អាតដៃ ថ្នាំសម្លាប់មេរោគ និងម៉ាសពាក់ការពារ។ នៅតាមសហគមន៍ដែលលទ្ធភាពក្នុងការទៅរកទឹកដែលគេផ្គត់ផ្គង់យកមកប្រើប្រាស់នៅមានកម្រិត ត្រូវផ្តល់ដល់ពួកគេនូវធុងទឹក និងឧបករណ៍សម្រាប់ជីកអណ្តូងជាបន្ទាន់។ រដ្ឋាភិបាលត្រូវធានាថា ទឹក និងសេវាអនាម័យ ត្រូវបានផ្តល់ឲ្យតាមរបៀបមួយដែលជួយដល់អ្នករស់នៅតាមទីតាំងទាំងនោះ អាចអនុវត្តបានយ៉ាងតឹងរឹងតាមវិធានការអនាម័យ និងគម្លាតសុវត្ថិភាព។

៤- ផ្តល់ឱ្យប្រជាជនរស់នៅតាមទីតាំងទាំងនោះនូវជំនួយក្នុងការបង្កើត ឬពង្រឹងរចនាសម្ព័ន្ធសហគមន៍មូលដ្ឋាន ដូច្នេះពួកគេអាចធ្វើការជាមួយរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពក្នុងការដោះស្រាយមេរោគរាតត្បាតនេះ។

៥- រៀបចំផែនការបន្ទាន់ដើម្បីជួយដល់ប្រជាជនរស់នៅតាមសំណង់មិនរៀបរយ/ទីតាំងរស់នៅលក្ខណៈប្រមូលផ្តុំមិនរៀបរយក្នុងកំឡុងពេលនៃការរីករាលដាលមេរោគដោយធ្វើការជាមួយមេដឹកនាំសហគមន៍ និងអ្នករស់នៅលើទីតាំង និងធានាថា ផែនការទាំងនេះត្រូវបានជជែកផ្លាស់ប្តូរយោបល់គ្នា។ មេដឹកនាំសហគមន៍ត្រូវតែទទួលបាននូវការអប់រំបណ្តុះបណ្តាលស្តីពីវិធានការណ៍សុវត្ថិភាពទាក់ទងនឹងមេរោគកូវីដ-១៩ ហើយគួរតែត្រូវបានអញ្ជើញឱ្យជួយដល់បុគ្គលិកដែលជាអ្នកផ្តល់សេវាកម្មចាំបាច់ក្នុងការផ្តល់នូវសេវាកម្មដែលត្រូវការនានា។

៦- ធានាថា ប្រជាជនរស់នៅតាមសំណង់មិនរៀបរយ/ទីតាំងរស់នៅលក្ខណៈប្រមូលផ្តុំមិនរៀបរយ មានលទ្ធភាពទៅប្រើប្រាស់សេវាសុខភាពសាធារណៈនិងឯកជនដោយគ្មានការរើសអើងដែលនៅជិតសហគមន៍របស់ពួកគេ និងធានាថា ការធ្វើតេស្តរកមេរោគកូវីដ-១៩ គឺមិនគិតថ្លៃ។ សេវាសុខភាព ត្រូវតែរៀបចំឲ្យមានសម្រាប់គ្រប់អ្នកដែលបានឆ្លងមេរោគ រួមទាំងតាមរយៈអ្នកផ្តល់សេវាសុខភាពក្រៅប្រព័ន្ធ ឬអ្នកផ្តល់សេវាសុខភាពតាមបែបបុរាណ ដែលពួកគេគួរតែត្រូវបាន បញ្ចូលក្នុងផែនការឆ្លើយតបរោគរាតត្បាតថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

៧- ធានាថា ម្ចាស់ផ្ទះជួលនៅតាមសំណង់មិនរៀបរយ ផ្តល់នូវការជួលបន្តដល់អ្នកដែលរងគ្រោះដោយមេរោគកូវីដ-១៩ និងហាមឃាត់ការកាត់ផ្តាច់សេវាកម្មទឹក និងអគ្គិសនីដល់គ្រួសារដែលមិនអាចទូទាត់

បង់វិក័យប័ត្រចំណាយក្នុងផ្ទះរបស់ពួកគេបាន។ គម្រោងអនុគ្រោះ បំណុល គួរតែត្រូវបានអនុវត្តដើម្បីជួយបន្ថយបន្ទុកហិរញ្ញវត្ថុដ៏ពិបាក ក្រោយពេលការឆ្លងរាលដាលនៃមេរោគ។

៨- បទប្បញ្ញត្តិបិទប្រទេស មិនគួរប៉ះពាល់ដល់សេវាកម្មសំខាន់ៗនៅតាមតំបន់សំណង់មិនរៀបរយ/ទីតាំងរស់នៅលក្ខណៈប្រមូលផ្តុំមិនរៀបរយ ដែលជាទូទៅសេវាកម្មនេះត្រូវបានផ្តត់ផ្គង់ដោយអ្នកធ្វើអាជីវកម្មក្រៅប្រព័ន្ធនៅមូលដ្ឋាន ដូចជា ការចែកចាយ និងលក់ម្ហូបអាហារឡើងវិញ ទឹក អុស ថាមពលអគ្គិសនី និងសម្ភារអនាម័យ ការផ្តល់មធ្យោបាយដឹកជញ្ជូនសង្គ្រោះបន្ទាន់ ការថែទាំកុមារ ជនមានពិការភាព មនុស្សចាស់ និងអ្នកដែលមានជំងឺ។

៩- អនុវត្តយុទ្ធនាការអប់រំជាសាធារណៈ និងធានាថា អ្នករស់នៅតាមតំបន់សំណង់មិនរៀបរយ/ទីតាំងរស់នៅលក្ខណៈប្រមូលផ្តុំមិនរៀបរយ ទទួលបានជាទៀតទាត់នូវព័ត៌មានទាក់ទងនឹងមេរោគកូវីដ-១៩ ការអនុវត្តល្អៗទាក់ទងនឹងការថែទាំសុខភាព គោលនយោបាយសុខភាពរបស់រដ្ឋាភិបាល និងការគាំទ្រដែលមាន។ ព័ត៌មាននេះត្រូវតែមានជាភាសាដែលអ្នកមូលដ្ឋានអាចងាយយល់បាន និងត្រូវចែកចាយតាមរយៈយន្តការផ្សេងៗ មិនត្រឹមតែតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមប៉ុណ្ណោះទេ។

១០- ទទួលស្គាល់ថា អ្នករស់នៅតាមតំបន់សំណង់មិនរៀបរយ/ទីតាំងរស់នៅលក្ខណៈប្រមូលផ្តុំមិនរៀបរយ តែងតែពឹងផ្អែកលើសេដ្ឋកិច្ចក្រៅប្រព័ន្ធដើម្បីជីវភាពរស់នៅរបស់ពួគេ និងធានាថា ការផ្តល់ជំនួយហិរញ្ញវត្ថុសង្គ្រោះបន្ទាន់ណាមួយដល់សេដ្ឋកិច្ចក្នុងប្រព័ន្ធដែលរងការប៉ះពាល់ដោយមេរោគរាតត្បាតត្រូវតែមានសម្រាប់ផ្តល់ដល់អ្នកដែលស្ថិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធផងដែរ ដូចនេះ ពួកគេ នឹងមិនរងគ្រោះដោយមិនសមាមាត្រពីការធ្លាក់ចុះនៃសេដ្ឋកិច្ច ដោយសារតែការរីករាលដាលមេរោគនោះទេ។

១១- ទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងពេលនៃការរីករាលដាលមេរោគ នឹងក្លាយជាកត្តាគន្លឹះក្នុងការធានាការឆ្លើយតបជាសកលដែលមានប្រសិទ្ធភាពក្នុងការការពារមនុស្សជាតិបានទាំងស្រុង។ ប្រទេសអ្នកមាន និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ត្រូវតែផ្អាក ឬលុបបំណុលពីប្រទេសក្រីក្រ។ ពួកគេ ក៏ត្រូវតែផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដោយផ្ទាល់ដល់ប្រទេសក្រីក្រដែលកំពុងតែធ្វើការការពារដល់ប្រជាជនរស់នៅតាមសំណង់មិនរៀបរយតាមរយៈការធានាអោយមានលំនៅឋានសមរម្យក្នុងអំឡុងពេលនិងក្រោយពេលនៃការរីករាលដាលមេរោគតាមលក្ខណៈមួយដែលអនុវត្តស្របតាមសិទ្ធិមនុស្ស។